00833745

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 13 / 08 / 2012
ម៉ោង (Time/Heure): 15:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

002/19-09-2007-ECCC/TC
E1/95

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ អង្គារ ទី ២៤ ខែ កក្កដា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្ដី - ថ្ងៃទី ៨៣

រៀបចំដោយ: ដាវ អានសាន និង Andrew James MCINTYRE

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្ដរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ដាវ អានសាន, លោក Andrew James MCINTYRE, លោក ឌុច ផារី, លោកស្រី Natacha Wexels-Riser |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក ច័ន្ទ តារាវស្មី, កញ្ញា សុង ឆវ័ន្ត, លោក Tarik ABDULHAK, លោក Salim NAKHJAVANI |
| ជនជាប់ចោទ៖ នួន ជា, ខៀវ សំផន, អៀង សារី (ពីបន្ទប់ខាងក្រោមសវនាការ) |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Andrew IANUZZI, លោក Jasper PAUW |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KANAVAS |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក ឡោ ជុនធី, លោក វ៉ែន ពៅ, លោក ហុង គីមសួន, លោកស្រី ស៊ិន សូវ៉ន |
| អ្នកជំនាញ៖ លោក David CHANDLER (TCE-11) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោក Simon MEISENBERG, លោក Jay GALIK |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ៩.០០ | បញ្ចប់ម៉ោង៖ ១៦.០០ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣៥ | បញ្ចប់ម៉ោង៖ ១១.០០ |
| សម្រាកអាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៤ ម៉ោង និង ៥០ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| សំណើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ដោយជនជាប់ចោទ | អៀង សារី<br>នួន ជា | ៩.០៧<br>១២.០៣ | ៩.០៩<br>១២.០៤ |
| ការសម្រេចលើសំណើសុំដាក់ឯកសាររបស់ក្រុមការពារក្តី អៀង សារី | អង្គជំនុំជម្រះ | ០៩.១១ | ០៩.១៥ |
| ការសម្រេចលើសំណើក្រុមការពារក្តី នួន ជា | អង្គជំនុំជម្រះ | ១៥.០៤ | ១៥.០៨ |
| ការតាំងសំណួរដល់អ្នកជំនាញ David Chandler | ក្រុមមេធាវី អៀង សារី<br>ក្រុមមេធាវី ខៀវ សំផន | ០៩.១៥<br>១៤.០៤ | ១៤.០២<br>១៦.០០ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

ប្រធានអង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើការនីតិវិធីសវនាការ ។

**ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់**

ជនជាប់ចោទ អៀង សារី (៩.០៧) និង នួន ជា (១២.០០) តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមការស្នើសុំ ។

**ការតាំងសំណួរដល់អ្នកជំនាញ David Chandler**

ការតាំងសំណួរដល់អ្នកជំនាញ David Chandler ដោយមេធាវីអន្តរជាតិការពារក្តីលោក អៀង សារី។ ការតាំងសំណួរនេះបន្តដោយមេធាវីជាតិការពារក្តីលោក ខៀវ សំផន។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/1691 | D288/4.59.1 | 00361467-00361553 00361336-00361466 00361582-00361721 | ប្រតិចារិតនៃដំណើរការនីតិវិធីជំនុំជម្រះករណី ឌុច - ០៦ សីហា ២០០៩ | P | 00361492, 00361534 | p. 58, 00361370, 00361436 | 00361619, 00361689 |
| E3/17 | D222/1.3 | 00392897-00393174 | [Surrogate Sheet] CHANDLER David, Brother Number One | P | | 00392985 | 00821734-00821736 |
| E3/12 | 6.3 | 00003136-00003142, 00000758-00000764 00182809-00182814 00224363-00224367 | សេចក្តីសំរេចរបស់គណៈមជ្ឈឹមអំពីបញ្ហាផ្សេងៗមួយចំនួន | P | 00003142, 00003141 | 00182814, 00182813 | 00224367, 00224366 |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យជនជាប់ចោទ អៀង សារី និង នួន ជា ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍

ទៅបន្ទប់រង់ចាំ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។

- អង្គជំនុំជម្រះសម្រេចបដិសេធសំណើសុំដាក់ឯកសារថ្មីរបស់ក្រុមការពារក្តី អៀង សារី សម្រាប់ដេញដោលអ្នកជំនាញ។ សំណើសុំនេះត្រូវបានធ្វើឡើងមិនទាន់ពេលវេលា និងមិនពាក់ព័ន្ធ។
- អង្គជំនុំជម្រះសម្រេចបដិសេធសំណើសុំផ្ទាល់មាត់របស់ក្រុមការពារក្តី នួន ជា ក្នុងការដាក់ឯកសារថ្មី។ សំណើត្រូវធ្វើជាលាយលក្ខណ៍អក្សរអនុលោមតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង។ ដោយឯកសារមានតែជាភាសាអង់គ្លេស ដូច្នេះត្រូវមានការបកប្រែជាភាសាខ្មែរផងដែរ។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ នាំអ្នកជំនាញត្រឡប់ទៅទីកន្លែងស្នាក់នៅ និងនាំគាត់ត្រឡប់មកសាលសវនាការវិញនៅថ្ងៃ ពុធ ទី២៥ ខែ កក្កដា ឆ្នាំ ២០១២ ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា, អៀង សារី និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ ដែលនៅពេលនោះ បន្ទាប់ពីទទួលបានការលះបង់សិទ្ធិរបស់ជនជាប់ចោទ អង្គជំនុំជម្រះនឹងសម្រេចថាតើអនុញ្ញាតឱ្យជនជាប់ចោទ បន្តតាមដានសវនាការពីបន្ទប់ខាងក្រោមសវនាការ។

| **<u>កាលបរិច្ឆេទបន្តសវនាការ៖</u>** |
| --- |
| សវនាការនឹងបន្តនៅថ្ងៃ ពុធ ទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

ដាវ ស៊ុនសាន Andrew James MCINTYRE